# កម្ពុជា ២០១៨

# ការស្ទង់មតិក្នុងរាជធានីភ្នំពេញ

## ការសិក្សាទីតាំងលំនៅឋានក្រីក្រក្នុងទីក្រុង រាជធានីភ្នំពេញ



CZECH REPUBLIC DEVELOPMENT COOPERATION

PEOPLE IN NEED CZECH REPUBLIC

សមាគមធានាត្នោត Sahmakum Teang Tnaut a Cambodian Urban NGO

UPWD

វិទ្យាស្ថានបើកទូលាយ Open Institute

# ការស្ទង់មតិក្នុងរាជធានីភ្នំពេញ
# ឆ្នាំ២០១៧

# មាតិកា


**មាតិកា** ..... i

**បញ្ជីពាក្យកាត់** ..... iv

**១. សេចក្តីផ្តើម** ..... ១

**២. វិធីសាស្ត្រ** ..... ៣

គោលបំណង ..... ៣

ការប្រមូលទិន្នន័យបឋម ..... ៣

និយមន័យ ទីតាំងលំនៅឋានក្រីក្រ ..... ៤

ក្រមសីលធម៌នៃការស្រាវជ្រាវ ..... ៥

ការគ្រប់គ្រងគុណភាព ..... ៦

ទិន្នន័យបន្ទាប់បន្សំ ..... ៦

វិសាលភាព និងដែនកំណត់ ..... ៦

ទីតាំងលំនៅឋានដែលមិនបានដាក់បញ្ចូល ..... ៦

ការយល់ដឹងរបស់អ្នកផ្តល់បទសម្ភាសន៍ ..... ៦

**៣. ទីតាំងលំនៅឋានក្រីក្រនៅទីប្រជុំជន** ..... ៧

លទ្ធផលរកឃើញ ..... ៧

លទ្ធផលរកឃើញសំខាន់ៗ ..... ១៤

**៤. ការកាន់កាប់ និងការចេញប័ណ្ណកម្មសិទ្ធិដីធ្លី និងការតាំងទីលំនៅថ្មី** ..... ១៥

ប្រភេទដីធ្លី និងប័ណ្ណកម្មសិទ្ធិដីធ្លី ..... ១៥

ប្រភេទដី ..... ១៥

ប្រភេទប័ណ្ណកម្មសិទ្ធិដីធ្លី ..... ១៦

លទ្ធផលរកឃើញ ........................................ ១៦

ប្រភេទដីធ្លី ........................................ ១៦

ប្លង់កម្មសិទ្ធិ ........................................ ១៧

ការផ្លាស់ប្តូរលំនៅឋាន ........................................ ១៨

លទ្ធផលរកឃើញសំខាន់ៗ ........................................ ២០

**៥. រចនាសម្ព័ន្ធលំនៅឋាន ហេដ្ឋារចនាសម្ព័ន្ធ និងសេវាផ្សេងៗ** ........................................ ២១

លទ្ធផលរកឃើញ ........................................ ២១

សម្ភារៈសម្រាប់សាងសង់លំនៅឋាន ........................................ ២១

ហេដ្ឋារចនាសម្ព័ន្ធទីតាំងលំនៅឋាន(ផ្លូវចូល) ........................................ ២២

ហេដ្ឋារចនាសម្ព័ន្ធទីតាំងលំនៅឋាន (ប្រព័ន្ធលូបង្ហូរទឹក) ........................................ ២៣

ហេដ្ឋារចនាសម្ព័ន្ធទីតាំងលំនៅឋាន( បង្គន់អនាម័យ) ........................................ ២៥

សេវាប្រមូលសំរាម ........................................ ២៥

សេវាទឹកស្អាត ........................................ ២៦

សេវាអគ្គិសនី ........................................ ២៧

**លទ្ធផលរកឃើញសំខាន់ៗ** ........................................ ២៧

**៦. សេចក្តីសន្និដ្ឋាន និងអនុសាសន៍** ........................................ ២៩

អនុសាសន៍ ........................................ ២៩

សាលារាជធានីភ្នំពេញ ........................................ ២៩

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្រ្ត និងការិយាល័យភូមិបាលខណ្ឌ ........................................ ២៩

ដៃគូអភិវឌ្ឍន៍ ........................................................................................................... ៣០

**៧. ផែនទីនៃទីតាំងលំនៅឋានក្រីក្រនៅរាជធានីភ្នំពេញ** ............................................................. ៣១

ឧបសម្ព័ន្ធទី ១ ៖ ទម្រង់នៃការស្ទង់មតិ ............................................................................... ៤៥

# បញ្ជីពាក្យកាត់

PPS2013 ........ ការស្ទង់មតិក្នុងរាជធានីភ្នំពេញ ឆ្នាំ២០១៣

GPS ........ ប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្រ

LMAP ........ កម្មវិធីរដ្ឋបាល និងគ្រប់គ្រងដីធ្លី

MLMUPC ........ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

MoP ........ ក្រសួងផែនការ

MPP ........ សាលារាជធានីភ្នំពេញ

SLR ........ ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ

STT ........ អង្គការសមាគមធាងត្នោត

SUPF ........ សម្ព័ន្ធសាមគ្គីភាពអ្នកក្រីក្រក្នុងទីក្រុង

# ១. សេចក្តីផ្តើម

របាយការណ៍នេះមានគោលបំណងបំពេញបន្ថែមទៅលើការស្រាវជ្រាវ និងព័ត៌មានស្តីពីទីតាំងលំនៅឋានក្រីក្រក្នុងរាជធានីភ្នំពេញ។ មានការសិក្សាសំខាន់ៗជាច្រើនដែលបានធ្វើឡើងស្តីពីទីតាំងលំនៅឋានក្រីក្រនៅរាជធានី និងការតាំងលំនៅឋានរបស់ពួកគេនៅក្នុងខណ្ឌខាងក្នុង និងខណ្ឌខាងក្រៅនៃរាជធានីភ្នំពេញ។ ការសិក្សាទាំងនេះបានប្រើប្រាស់វិធីសាស្ត្រច្រើនដើម្បីប្រមូលទិន្នន័យពីទីតាំងលំនៅឋាន និងគ្រួសារក្រីក្រនៅរាជធានីភ្នំពេញដូចជា ព័ត៌មានពីការគំរាមកំហែងនិងការបណ្តេញចេញ ការចេញប័ណ្ណកម្មសិទ្ធិដីធ្លី និងការចាត់ថ្នាក់ប្រភេទដីធ្លី ព្រមទាំងស្ថានភាពសេដ្ឋកិច្ចសង្គមទូទៅ។ ការសិក្សាកន្លងមករួមមាន៖

- **ស្ថានភាពនៃទីតាំងលំនៅឋានរបស់ក្រីក្រក្នុងរាជធានីភ្នំពេញក្នុងព្រះរាជាណាចក្រកម្ពុជា៖** របាយការណ៍នេះបានធ្វើឡើងនៅក្នុងឆ្នាំ ១៩៩៧ ដោយសហគមន៍មូលដ្ឋានដែលបច្ចុប្បន្នគេស្គាល់ថាជាសហព័ន្ធសាមគ្គីភាពអ្នកក្រីក្រ(SUPF)[1]។ វាជាការស្ទង់មតិជាសាធារណៈមានលក្ខណៈទូលំទូលាយលើកដំបូងស្តីពីទីតាំងលំនៅឋានរបស់អ្នកក្រីក្រនៅក្នុងរាជធានីភ្នំពេញ។ នៅពេលនោះ គេបានរកឃើញថាមានតំបន់ក្រីក្រចំនួន៣៧៩ ហើយមានប្រជាពលរដ្ឋសរុបចំនួន ១៨០ ០០០នាក់នៅក្នុងរាជធានីភ្នំពេញបានរស់នៅក្នុង "តំបន់មិនរៀបរយ"។
- **រាជធានីភ្នំពេញ "សៀវភៅព័ត៌មានស្តីពីការអភិវឌ្ឍទីក្រុង និងទីតាំងលំនៅឋានរបស់អ្នកក្រីក្រនៅរាជធានី"៖** របាយការណ៍នេះបានធ្វើឡើងម្តងទៀតដោយ SUPF នៅក្នុង ឆ្នាំ២០០៣ វាជាការតាមដានការស្ទង់មតិក្នុងឆ្នាំ១៩៩៧ ដែលរួមបញ្ចូលទិន្នន័យបន្ថែមពីខណ្ឌខាងក្រៅពីរាជធានីភ្នំពេញ។ លទ្ធផលរកឃើញ សំខាន់ៗបានបង្ហាញថាទំហំនៃភាពក្រីក្រគឺកាន់តែលំបាកទៅៗនៅក្នុងខណ្ឌខាងក្រៅ ដែលជាទីតាំងលំនៅឋានថ្មីត្រូវបានបង្កើតឡើង ហើយសហគមន៍ ៤០% ស្ថិតនៅក្រោមការគំរាមកំហែងនៃការបណ្តេញចេញ។
- **ការស្ទង់មតិខណ្ឌទាំង៨ "ការសិក្សាអំពីការតាំងលំនៅឋានក្រីក្រនៅក្នុងរាជធានីភ្នំពេញ"៖** នៅឆ្នាំ ២០០៩ អង្គការសមាគមធាងត្នោតបានធ្វើការសិក្សាស្រាវជ្រាវនេះ ដើម្បីពង្រឹងបន្ថែមទៅលើការស្ទង់មតិដែលបានធ្វើពីមុនៗមក។ អង្គការបានរកឃើញទីតាំងក្រីក្រចំនួន ៤១០ ដោយមានគ្រួសារក្រីក្រសរុបចំនួន ៤០ ៥៤៨ គ្រួសារនៅក្នុងខណ្ឌទាំង៨។ អ្វីដែលសំខាន់នោះគឺថា នៅឆ្នាំ ១៩៩៧ ជិតពាក់កណ្តាលនៃអ្នកក្រីក្រក្នុងរាជធានីភ្នំពេញរស់នៅក្នុងខណ្ឌខាងក្នុង ដែលចំនួននេះបានធ្លាក់ចុះជិតដល់២៥%ក្នុងឆ្នាំ២០០៩ ដែលនេះបង្ហាញពីការផ្លាស់ប្តូរទីតាំងដ៏ច្រើនរបស់អ្នកក្រីក្រនៅរាជធានីពីខណ្ឌខាងក្នុងទៅខណ្ឌខាងក្រៅ។
- **របាយការណ៍ស្ថានភាពសហគមន៍អ្នកក្រីក្រ រាជធានីភ្នំពេញ៖** នៅឆ្នាំ ២០១២ សាលារាជធានីភ្នំពេញបានធ្វើការសិក្សាជាមូលដ្ឋានរបស់ខ្លួនស្តីពីស្ថានភាពសហគមន៍ក្រីក្ររាជធានីភ្នំពេញ ដើម្បីផ្តល់នូវទិដ្ឋភាពទូទៅនៃស្ថានភាពរស់នៅ ស្ថានភាពសេដ្ឋកិច្ច-សង្គម និងការផ្តល់សេវាសង្គម។ យោងតាមការសិក្សានេះមានទីតាំង

[1] ពីមុនស្ថាប័ននេះមានឈ្មោះថាសម្ព័ន្ធអ្នកតាំងទីលំនៅក្រីក្រក្នុងទីក្រុង(SUPF)

ចំនួន៥១៦ នៃសហគមន៍ក្រីក្រនៅក្នុងរាជធានីភ្នំពេញ ដែលក្នុងនោះទីតាំងចំនួន៣៤២ ត្រូវបានចងក្រង និង ចំនួន១៧៤ មិនបានចងក្រង។

- **ការស្ទង់មតិនៅក្នុងរាជធានីភ្នំពេញ “ការសិក្សាអំពីការអង្កេតពីតំបន់ក្រីក្រក្នុងរាជធានីភ្នំពេញ”** ការស្ទង់មតិក្នុងរាជធានីភ្នំពេញឆ្នាំ២០១៣៖ ការស្រាវជ្រាវនេះធ្វើឡើងដោយអង្គការសមាគមធាងត្នោតក្នុងឆ្នាំ២០១៣ (បោះពុម្ពផ្សាយក្នុងឆ្នាំ ២០១៤) មានគោលបំណងធ្វើបច្ចុប្បន្នភាព និងដើម្បីផលិតផែនទីនៃទីតាំងក្រីក្រនៅក្នុងខណ្ឌទាំង៨ ក្នុងរាជធានីភ្នំពេញ។ ការស្ទង់មតិនេះបានបង្ហាញពីទីតាំងលំនៅឋានរបស់អ្នកក្រីក្រចំនួន ៣៤០ ដែលស្ថានភាពជីវភាពរស់នៅរបស់ពួកគេនៅតែត្រូវការធ្វើឱ្យប្រសើរឡើង។

# ២. វិធីសាស្ត្រ

## គោលបំណង

គោលបំណងនៃរបាយការណ៍នេះគឺមានដូចខាងក្រោម៖

- ធ្វើបច្ចុប្បន្នភាព និងប្រមូលទិន្នន័យថ្មីៗនៃទីតាំងលំនៅឋានក្រីក្រនៅក្នុងរាជធានីភ្នំពេញដែលបានសិក្សាស្រាវជ្រាវកន្លងមក "ការស្ទង់មតិក្នុងរាជធានីភ្នំពេញ" របស់អង្គការសមាគមធាងត្នោតកាលពីឆ្នាំ២០១៤ និងកំណត់នូវទីតាំងលំនៅឋានសំខាន់ៗថ្មីៗបន្ថែមទៀត។
- ផលិតផែនទី និងធ្វើបច្ចុប្បន្នភាពឱ្យបានត្រឹមត្រូវនៃទីតាំងលំនៅឋានក្រីក្រនៅក្នុងរាជធានីភ្នំពេញ។
- បង្ហាញពីលទ្ធផលរកឃើញ និងផ្តល់អនុសាសន៍នានាដល់ភាគីពាក់ព័ន្ធសំខាន់ៗ ដើម្បីឱ្យមានលទ្ធផលវិជ្ជមានសម្រាប់ប្រជាជនក្រីក្រទាំងនោះ។

## ការប្រមូលទិន្នន័យបឋម

ការស្ទង់មតិនេះធ្វើឡើង ដោយផ្អែកលើឯកសារស្ទង់មតិក្នុងរាជធានីភ្នំពេញឆ្នាំ២០១៣ ដើម្បីអាចប្រៀបធៀបទិន្នន័យរវាងឆ្នាំ២០១៣ និងឆ្នាំ២០១៧។ មាតិកាភាគច្រើនមិនមានការផ្លាស់ប្តូរទេ លើកលែងតែចំនួនពីរផ្នែកត្រូវបានដកចេញដែលចាត់ទុកថាលែងចាំបាច់។[2] កម្រងសំណួរទាំងអស់បានបំប្លែងដោយប្រើកម្មវិធី អូឌីខេ (ODK) ដែលជាកម្មវិធីប្រមូលទិន្នន័យដោយប្រើឧបករណ៍អេឡិចត្រូនិកចល័ត ដូចជាទូរសព្ទស្មាតហ្វូន (Smart Phone) ឬថេប្លេត (Tablet) ។

អ្នកប្រមូលទិន្នន័យចំនួន១០នាក់ និងប្រធានក្រុមម្នាក់បានទទួលការបណ្តុះបណ្តាលអំពីការប្រមូលទិន្នន័យ ដោយប្រើកម្មវិធី ODK និងប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្រ(GPS) ដែលមាននៅក្នុងថេប្លេត។ អ្នកប្រមូលទិន្នន័យបានធ្វើការជាគូៗ ដោយបានផ្តល់ទីតាំងកូអរដោនេប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្រ (ដំឡើងក្នុងថេប្លេត) នៃទីតាំងលំនៅឋានចំនួន ៣៤០ ដែលបានធ្វើការស្ទង់មតិក្នុងរាជធានីភ្នំពេញកាលពីឆ្នាំ ២០១៣ ។

ការស្ទង់មតិនេះបានធ្វើឡើងក្នុងរាជធានីភ្នំពេញនៅខែសីហា ឆ្នាំ២០១៧ ដោយក្រុមអ្នកប្រមូលទិន្នន័យនៅទីតាំងចំនួន ៣៤០កន្លែង ដែលក្នុងនោះ ទីតាំងចំនួន ២៧៧កន្លែង ត្រូវបានចាត់ទុកថាជាទីតាំងលំនៅឋានក្រីក្រនៅរាជធានី និងបានបញ្ចូលទីតាំងទាំងនោះទៅក្នុងការវិភាគ។ ក្រុមគោលដៅសម្រាប់សម្ភាសនៅតាមទីតាំងនីមួយៗមានដូចជា ប្រធានភូមិ ឬចៅសង្កាត់ ឬអ្នកដឹកនាំសហគមន៍ ក្នុងករណីប្រធានភូមិ ឬចៅសង្កាត់មិន ទំនេរ។

---

[2] ផ្នែកទី ៥៖ ទ្រព្យសម្បត្តិ សន្តិសុខ និងមូលនិធិសង្គមរបស់ទីតាំងលំនៅឋាន និងផ្នែកទី ៦៖ គ្រោះថ្នាក់ និងហានិភ័យ

ប្រសិនបើមិនមានប្រធានភូមិ ឬចៅសង្កាត់ ឬអ្នកដឹកនាំសហគមន៍ទេ យើងសម្ភាសប្រជាពលរដ្ឋដែលរស់នៅទីតាំងនោះ។ ខាងក្រោមនេះជាតារាងអ្នកបានផ្ដល់បទសម្ភាសៈ[3]

| | | |
|---|---|---|
| ប្រធានភូមិ ឬចៅសង្កាត់ | ៥៧ | ២១% |
| អ្នកដឹកនាំ ឬតំណាងសហគមន៍ | ៣៩ | ១៤% |
| ប្រជាពលរដ្ឋដែលរស់នៅទីតាំងលំនៅឋានក្រីក្រ | ១៨១ | ៦៥% |
| **សរុប** | **២៧៧** | |

ក្រុមអ្នកប្រមូលទិន្នន័យ និងប្រធានក្រុមបានពិភាក្សាជាមួយប្រធានភូមិ និងបានធ្វើដំណើរជុំវិញខណ្ឌទាំង១២ ដើម្បីស្វែងរកទីតាំងលំនៅឋានផ្សេងៗទៀត ដែលមិនបានដាក់បញ្ចូលទៅក្នុងការស្ទង់មតិពីមុនៗ។ ទីតាំងលំនៅឋានថ្មីៗដែលបានរកឃើញត្រូវបានដាក់លេខកូដ និងសញ្ញាសម្គាល់ថ្មីផងដែរ។ ក្រុមអ្នកសិក្សាស្រាវជ្រាវបានត្រួតពិនិត្យនិងផ្ទៀងផ្ទាត់ចំនុចទីតាំងប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្រ (GPS) ដើម្បីធានាថាទីតាំងទាំងនោះត្រឹមត្រូវ។ ក្នុងករណីចាំបាច់ ប្រធានក្រុមអ្នកស្រាវជ្រាវបានចុះទៅសហគមន៍ជាច្រើនដងដើម្បីបំពេញនិងបញ្ជាក់ព័ត៌មានបន្ថែមឱ្យកាន់តែច្បាស់លាស់។

## និយមន័យ ទីតាំងលំនៅឋានក្រីក្រ

មានការប្រើពាក្យខុសគ្នាជាច្រើនអំពីទីតាំង និងលំនៅឋានក្រីក្រក្នុងទីក្រុង នៅជុំវិញពិភពលោក ប៉ុន្តែវាពិបាកកំណត់រកពាក្យតែមួយណាស់។ តំបន់ក្រីក្រមួយចំនួនអាចមានលំនៅឋាន និងហេដ្ឋារចនាសម្ព័ន្ធជាច្រើនរួមមាន ហាងទំនិញ សាលារៀន និងសេវាសង្គមផ្សេងៗទៀត។ ចំណែកឯទីតាំងលំនៅឋានក្រីក្រមួយចំនួនផ្សេងទៀតអាចជាផ្ទះតូចៗជាច្រើនជាប់ៗគ្នាដែលមិនមានអ្វីផ្សេងទៀតនៅជុំវិញនោះ។ នៅក្នុងប្រទេសកម្ពុជារាជរដ្ឋាភិបាលកំណត់គ្រួសារក្រីក្រតាមរយៈការផ្ដល់បណ្ណក្រីក្រ។ ប៉ុន្តែការសិក្សាស្រាវជ្រាវនេះមិនអាចប្រើប្រាស់ទិន្នន័យទាំងនោះបានទេ ព្រោះទិន្នន័យទាំងនោះមិនទាន់បានធ្វើចប់សព្វគ្រប់នៅឡើយ។ សម្រាប់គោលបំណងនៃការស្រាវជ្រាវនេះ និយមន័យជាមូលដ្ឋានមួយត្រូវបានប្រើប្រាស់សម្រាប់ទីតាំងលំនៅឋានក្រីក្រនៅរាជធានីភ្នំពេញ ប៉ុន្តែដើម្បីផ្ដល់នូវភាពបត់បែនក្នុងការទទួលយកការឱ្យនិយមន័យនៃទីតាំងលំនៅឋានក្រីក្រនៅទីប្រជុំជនដែលមានលក្ខណៈផ្សេងៗពីគ្នា ហើយមានលក្ខណៈវិនិច្ឆ័យបន្ថែមមួយចំនួនបានប្រើប្រាស់។ ទីតាំងលំនៅឋានក្រីក្រនៅទីប្រជុំជនត្រូវបានកំណត់ថាជា "សំណង់លំនៅឋានជាប់ៗគ្នាចាប់ពី១០ខ្នងឡើងទៅដែលមានរចនា-

[3] នៅក្នុងការស្ទង់មតិក្នុងរាជធានីភ្នំពេញ ឆ្នាំ ២០១៣ មានតែ៦% នៃការសម្ភាសប៉ុណ្ណោះត្រូវបានធ្វើឡើងជាមួយនឹងប្រធានភូមិ ឬមេឃុំ និង ៦៤% ជាមួយប្រជាជនដែលរស់នៅទីតាំងលំនៅឋានទាំងនោះ។

សម្ព័ន្ធលំនៅឋានមានសោភ័ណភាព គុណភាពមិនល្អ និង ឬ លំនៅឋានដែលសាងសង់ដោយគ្មានរចនាបថច្បាស់លាស់ ព្រមទាំងមិនអនុលោមតាមប្លង់គោល "។[4] មានការឱ្យនិយមន័យបន្ថែមទៀតដូចជា គ្រួសារដប់ ឬច្រើនជាងដប់ដែលរស់នៅក្នុងលំនៅឋានដែលខ្វះលក្ខណៈវិនិច្ឆ័យដូចទៅនឹងនិយមន័យរបស់អង្គការលំនៅឋានពិភពលោកស្តីពីតំបន់មិនរៀបរយត្រូវបានគេចាត់ថ្នាក់ជាទីតាំងលំនៅឋានក្រីក្រនៅទីប្រជុំជនផងដែរ។ លក្ខណៈវិនិច្ឆ័យរួមមានដូចខាងក្រោម៖

- ជាលំនៅឋានជាប់លាប់ និងអចិន្ត្រៃយ៍ដែលអាចការពារពីការប្រែប្រួលអាកាសធាតុផ្សេងៗ។
- មានទំហំសមរម្យដែលមានមនុស្សមិនលើសពីបីនាក់រស់នៅក្នុងបន្ទប់រួម។
- ងាយស្រួលទទួលបានទឹកស្អាតប្រើប្រាស់គ្រប់គ្រាន់ក្នុងតម្លៃសមរម្យ។
- ទទួលបានបង្គន់អនាម័យឯកជន ឬសាធារណៈគ្រប់គ្រាន់ដែលអាចប្រើប្រាស់បានតាមចំនួនមនុស្សសមស្រប។
- មានសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លីដែលការពារពីការបណ្តេញចេញដោយបង្ខំ

## ក្រមសីលធម៌នៃការស្រាវជ្រាវ

អង្គការសមាគមធាងត្នោតធ្វើការយ៉ាងជិតស្និទ្ធជាមួយសហគមន៍ក្រីក្រនៅក្នុងរាជធានីភ្នំពេញ និងមានទំនាក់ទំនងយ៉ាងច្រើនជាមួយសហគមន៍ទាំងនោះ។ ដើម្បីធានាថាការប្រមូលទិន្នន័យប្រព្រឹត្តទៅដោយមិនលម្អៀង និងបានអនុវត្តប្រកបដោយក្រមសីលធម៌ក្នុងការស្រាវជ្រាវនេះ គោលការណ៍នៃការសម្ភាសត្រូវបានពន្យល់ដល់អ្នកចូលរួមទាំងអស់ដូចខាងក្រោម៖

- ការចូលរួមដោយស្ម័គ្រចិត្ត
- រក្សាការសម្ងាត់
- អនាមិកភាព
- ប្រាប់ពីគោលបំណង និងលទ្ធផលនៃការស្រាវជ្រាវ
- ធានាជូនអ្នកចូលរួមថា ព័ត៌មានដែលពួកគេបានចែករំលែកនឹងត្រូវបានប្រើប្រាស់សម្រាប់តែគោលបំណងសិក្សាស្រាវជ្រាវ និងសម្រាប់ការតស៊ូមតិប៉ុណ្ណោះ។
- ការយល់ព្រមដោយមានការជូនដំណឹងជាមុន មានន័យថាអ្នកចុះប្រមូលទិន្នន័យត្រូវសុំការយល់ព្រមជាពាក្យសម្តីពីអ្នកចូលរួមមុនពេលចាប់ផ្តើមការស្ទង់មតិ។

---

[4] និយមន័យនេះត្រូវបានប្រើប្រាស់ដោយអង្គការសមាគមធាងត្នោតក្នុងការស្ទង់មតិចំនួនពីរ ពីមុនអំពីប្រជាពលជនក្រីក្រនៅទីក្រុងកាលពីឆ្នាំ ២០០៩ និងឆ្នាំ ២០១៣។ ស្រដៀងគ្នានេះដែរ វាគឺជានិយមន័យដែលត្រូវបានប្រើប្រាស់ដោយអង្គការយូនីសេហ្វ និងអង្គការដៃគូ ភីពផលអ៊ីននីត(ភីន)។ សូមមើលការវាយតម្លៃសូចនាករជាច្រើននៃប្រជាជនក្រីក្រនៅទីក្រុង(ឆ្នាំ២០១៤)
https://www.unicef.org/cambodia/results_for_children_23397.html.

## ការគ្រប់គ្រងគុណភាព

ប្រធានក្រុមអ្នកស្រាវជ្រាវបានចុះអង្កេតការងាររបស់ក្រុមអ្នកប្រមូលទិន្នន័យ ក្នុងការប្រាស្រ័យទាក់ទងជាមួយនឹងអ្នកចូលរួមក្នុងពេលសម្ភាស ដើម្បីធានានូវគុណភាពនៃការសម្ភាស។ ទិន្នន័យសម្រាប់ការស្ទង់មតិនេះត្រូវបានប្រមូលដោយប្រើប្រាស់កម្មវិធី ODK នៅលើថេប្លេត។ ការធ្វើបែបនេះ បានជួយក្នុងការប្រមូលទិន្នន័យឱ្យកាន់តែមានភាពត្រឹមត្រូវជាងមុន ពីព្រោះថាទិន្នន័យអាចត្រូវបានត្រួតពិនិត្យឡើងវិញក្នុងពេលប្រមូលទិន្នន័យជាក់ស្តែង ដោយមិនចាំបាច់ចំណាយពេលបញ្ចូលទិន្នន័យម្តងទៀតទេ។

## ទិន្នន័យបន្ទាប់បន្សំ

ទិន្នន័យបន្ទាប់បន្សំដែលបានប្រើប្រាស់នៅក្នុងរបាយការណ៍នេះបានទទួលពីប្រភពផ្សេងៗជាច្រើន រួមមានរបាយការណ៍អង្គការសង្គមស៊ីវិល របាយការណ៍រាជរដ្ឋាភិបាល ឯកសារស្រាវជ្រាវ អត្ថបទសារព័ត៌មាន និងបោះពុម្ពផ្សាយនានាដែលអាចរកបាន។

## វិសាលភាព និងដែនកំណត់

### ទីតាំងលំនៅឋានដែលមិនបានដាក់បញ្ចូល

ខណៈពេលដែលអ្នកប្រមូលទិន្នន័យបានកំណត់ទីតាំងលំនៅឋានតាមរយៈកូអរដោនេប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្រ ក្នុងឆ្នាំ២០១៣ និងការធ្វើដំណើរតាមផ្លូវក្នុងខណ្ឌនីមួយៗនៃខណ្ឌទាំង១២ ក៏ដូចជាការសាកសួរព័ត៌មានពីអាជ្ញាធរមូលដ្ឋាន គឺថាមានទីតាំងលំនៅឋានក្រីក្រមួយចំនួនមិនបានរកឃើញ និងមិនបានដឹងហើយក៏មិនបានដាក់បញ្ចូលក្នុងការស្រាវជ្រាវនេះដែរ។

### ការយល់ដឹងរបស់អ្នកផ្តល់បទសម្ភាសន៍

ទិន្នន័យការស្ទង់មតិពឹងផ្អែកទាំងស្រុងលើការយល់ដឹងរបស់អ្នកផ្តល់បទសម្ភាសន៍ដើម្បីអាចឆ្លើយសំណួរអំពីទីតាំងលំនៅឋានក្រីក្រទាំងអស់ រួមទាំងការប៉ាន់ស្មានពីចំនួនខ្នងផ្ទះ ចំនួនគ្រួសារ និងការយល់ដឹងអំពីសិទ្ធិកាន់កាប់ដីធ្លីស្របច្បាប់។ ក្នុងករណីដែលគ្មានទិន្នន័យដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់ ឬមិនបានសម្ភាសអ្នកតំណាងទីតាំងនោះ អង្គការសមាគមធាងត្នោតមិនអាចផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃព័ត៌មានដែលផ្តល់ដោយអ្នកផ្តល់ចម្លើយទេ ដូច្នេះគឺត្រូវពឹងផ្អែកទាំងស្រុងលើការសន្និដ្ឋានរបស់ខ្លួន។

## ៣. ទីតាំងលំនៅឋានក្រីក្រនៅទីប្រជុំជន

រាជធានីភ្នំពេញបានបែងចែកជា ១២ ខណ្ឌ។ ខណ្ឌចំនួន៤ បានចាត់ទុកថាជាខណ្ឌ ខាងក្នុងរាជធានីភ្នំពេញ មានដូចជាខណ្ឌដូនពេញ ខណ្ឌចំការមន ខណ្ឌទួលគោក និងខណ្ឌ៧មករា។ ខណ្ឌទាំង៤ នេះមានចម្ងាយប្រមាណជា ៣,៥ គីឡូម៉ែត្រពីចំណុចកណ្តាលនៃរាជធានីភ្នំពេញ ហើយមានផ្ទៃដី ២៨ គីឡូម៉ែត្រការ៉េ ឬ ៤% នៃផ្ទៃដីរាជធានីភ្នំពេញ។ គេចាត់ទុកខណ្ឌ៨ផ្សេងទៀតថាជាខណ្ឌខាងក្រៅនៃរាជធានីភ្នំពេញ ដែលមានចម្ងាយប្រហែល ២០ គីឡូម៉ែត្រពីចំណុចកណ្តាលនៃរាជធានីភ្នំពេញ។

ជំពូកបន្ទាប់នេះ បង្ហាញពីទិន្នន័យសំខាន់ៗស្តីពីទីតាំងលំនៅឋានក្រីក្រនៅក្នុងរាជធានីភ្នំពេញដែលត្រូវបានកំណត់ដោយការស្ទង់មតិនៅឆ្នាំ២០១៧។


សហគមន៍និរោធបឹងឈូកឆ្នាំ២០១៧

## លទ្ធផលរកឃើញ

### ការថយចុះចំនួនទីតាំងលំនៅឋានក្រីក្រនៅក្នុងរាជធានីភ្នំពេញ

សរុបមក ការស្ទង់មតិនៅក្នុងរាជធានីភ្នំពេញឆ្នាំ២០១៧ បានរកឃើញថាមានទីតាំងលំនៅឋានក្រីក្រនៅរាជធានីភ្នំពេញចំនួន២៧៧ទីតាំង។ ទីតាំងលំនៅឋានក្រីក្រទាំងនោះបានថយចុះជាបន្តបន្ទាប់ពីការស្រាវជ្រាវ

ដែលអង្គការសមាគមផាងត្នោតបានរកឃើញពីមុនៗមក ដែលក្នុងនោះមានទីតាំងចំនួន៦៣បានថយចុះ បើប្រៀបធៀបទៅនឹងការស្ទង់មតិឆ្នាំ២០១៣ ដែលពេលនោះលំនៅឋានក្រីក្រមានចំនួន៣៤០ទីតាំង គឺថយចុះ ១៨% ក្នុងរយៈពេលជាង ៤ ឆ្នាំ។

**តារាងទី ១៖** ចំនួនទីតាំងលំនៅឋានក្រីក្រនៅរាជធានីភ្នំពេញចន្លោះឆ្នាំ ១៩៩៧ និង ២០១៧[5]

| **ខណ្ឌខាងក្នុង** | **១៩៩៧** | **២០០៣** | **២០០៩** | **២០១៣** | **២០១៧** |
|---|---|---|---|---|---|
| ៧ មករា | ៥៧ | ៥៨ | ៣០ | ១៧ | ៩ |
| ចំការមន | ៦៧ | ៦៨ | ២៩ | ២៥ | ១៩ |
| ដូនពេញ | ៧២ | ៨១ | ៣២ | ១៧ | ១៣ |
| ទួលគោក | ៦០ | ៤៨ | ៣៨ | ២១ | ១៥ |
| **សរុប** | **២៥៦** | **២៥៥** | **១២៩** | **៨០** | **៥៦** |
| | **៧១%** | **៦០%** | **៣៦%** | **២៥%** | **២០%** |
| **ខណ្ឌខាងក្រៅ** | **១៩៩៧** | **២០០៣** | **២០០៩** | **២០១៣** | **២០១៧** |
| ច្បារអំពៅ | មិនមាន | មិនមាន | មិនមាន | មិនមាន | ៣៦ |
| ជ្រោយចង្វារ | មិនមាន | មិនមាន | មិនមាន | មិនមាន | ១៣ |
| ដង្កោ | ១៦ | ១៤១ | ៥៤ | ២៥ | ២៣ |
| មានជ័យ | ៤៦ | ៩៤ | ៩៣ | ៨៩ | ៤១ |
| ពោធិ៍សែនជ័យ | មិនមាន | មិនមាន | មិនមាន | ២៨ | ១៩ |
| ឫស្សីកែវ | ៦១ | ៧៩ | ៩៦ | ៨៧ | ៥២ |
| សែនសុខ | មិនមាន | មិនមាន | ៣៨ | ៣១ | ២៧ |
| ព្រែកព្នៅ | មិនមាន | មិនមាន | មិនមាន | មិនមាន | ១០ |
| **សរុប** | **១០៧** | **១៧៣** | **២២៧** | **២៣៥** | **២២១** |
| | **២៩%** | **៤០%** | **៦៤%** | **៧៥%** | **៨០%** |
| **សរុបរួម** | **១៩៩៧** | **២០០៣** | **២០០៩** | **២០១៣** | **២០១៧** |
| | **៣៧៩** | **៥៦៩** | **៤១០** | **៣៤០** | **២៧៧** |

[5] នៅឆ្នាំ ២០១១ រាជធានីភ្នំពេញបានពង្រីកបន្ថែម ដើម្បីដាក់បញ្ចូលខណ្ឌពោធិ៍សែនជ័យ និងឆ្នាំ ២០១៥ រាជធានីភ្នំពេញត្រូវបានបែងចែកបន្ថែមទៅជាខណ្ឌចំនួន ១២ ដើម្បីដាក់បញ្ចូលច្បារអំពៅ ជ្រោយចង្វារ និងព្រែកព្នៅ។

ក្រាហ្វិកខាងក្រោមនេះ ក៏ជួយបង្ហាញពីនិន្នាការធ្លាក់ចុះចំនួនទីតាំងលំនៅឋានក្រីក្រក្នុងរាជធានីភ្នំពេញ ដែលបានរកឃើញដោយអង្គការសមាគមជាងត្នោត។

**តួលេខទី ១៖** ចំនួនសរុបទីតាំងលំនៅឋានក្រីក្រនៅរាជធានីភ្នំពេញនៅខណ្ឌខាងក្នុង និងខណ្ឌខាងក្រៅ ឆ្នាំ ១៩៩៧-២០១៧




ការស្ទង់មតិក្នុងរាជធានីភ្នំពេញ ឆ្នាំ២០១៧ បានកំណត់រកឃើញទីតាំងលំនៅឋានក្រីក្រថ្មីៗចំនួន៥ ទីតាំងដែលក្នុងនោះ មានលំនៅឋានចំនួន២ដែលជាទីតាំងផ្លាស់ប្តូរទីលំនៅ (ទីតាំងលំនៅឋានដែលត្រូវបានគេបណ្តេញចេញ) ហើយទីតាំងលំនៅឋានដែលបានបង្កើតឡើងថ្មីចំនួនមានចំនួន២ទីតាំងបន្ថែមទៀត (បន្ទាប់ពីការស្រាវជ្រាវបានធ្វើឡើងសម្រាប់ការស្ទង់មតិក្នុងរាជធានីភ្នំពេញឆ្នាំ២០១៣) និងទីតាំងលំនៅឋានមួយផ្សេងទៀតគឺជាទីតាំងលំនៅឋានដែលកើតឡើងដោយទីតាំងចំនួនបួនដែលរីកទំហំធំឡើងៗ ហើយត្រូវបានចាត់ទុកទីតាំងដោយឡែកថ្មីមួយទៀតសម្រាប់ការស្ទង់មតិឆ្នាំ២០១៧។ ជារួម មានទីតាំងលំនៅឋានចំនួន៦៦ ដែលមាននៅក្នុងអំឡុងពេលនៃការស្ទង់មតិក្នុងរាជធានីភ្នំពេញឆ្នាំ២០១៣ បានដកចេញពីការស្ទង់មតិក្នុងរាជធានីភ្នំពេញឆ្នាំ ២០១៧ ដោយហេតុផលផ្សេងៗជាច្រើនដែលបានបង្ហាញនៅក្នុងតារាងខាងក្រោម៖

**តារាងទី ២៖** ទីតាំងលំនៅឋានដែលបានដកចេញពីការស្ទង់មតិក្នុងរាជធានីភ្នំពេញនៅ ឆ្នាំ២០១៧

| | | |
|---|---|---|
| ទីតាំងលំនៅឋានមានទំហំតូច (តិចជាង ១០ ខ្នងផ្ទះ)[6] | ១៤ | ២១% |
| ទីតាំងលំនៅឋានដែលមានលក្ខខណ្ឌល្អប្រសើរ (មិនមានលំនៅឋានក្រីក្រ)[7] | ៣៥ | ៥៣% |
| ទីតាំងលំនៅឋានបានបាត់បង់ ដោយសារការអភិវឌ្ឍ (ដោយរាជរដ្ឋាភិបាល ឬភាគីឯកជន) ជំនួសមកវិញដោយអគារ ឬផ្ទះល្វែងថ្មីៗ ដីទំនេរ និងអគារកំពុងសាងសង់ ។ល។[8] | ១៤ | ២១% |
| ទីតាំងដែលបានចាត់បញ្ចូលជាផ្នែកនៃទីតាំងធំណាមួយ[9] | ៣ | ៥% |
| **សរុប** | **៦៦** | |

នៅឆ្នាំ២០១៣ ក្នុងចំណោមទីតាំងលំនៅឋានដែលបានដកចេញ មានទីតាំងលំនៅឋានចំនួន ៥០% បាន "បាត់" ហើយមានតែទីតាំងលំនៅឋានចំនួន ១៣% បានបង្ហាញលក្ខខណ្ឌល្អប្រសើរឡើង។ ស្ថានភាពនៅឆ្នាំ ២០១៧ ហាក់ដូចជាបង្ហាញពីភាពវិជ្ជមានបន្ថែមទៀត ដោយសារជាងពាក់កណ្ដាល(៥៣%) នៃទីតាំងលំនៅឋានដែលត្រូវបានដកចេញទាំងអស់គឺដោយសារតែការកែលម្អនូវស្ថានភាពជីវភាពរស់នៅ ដូចជាអគាររឹងមាំ ផ្លូវថ្នល់កាន់តែប្រសើរ ការទទួលបានបរិក្ខារប្រើប្រាស់ (ភ្លើង ឬទឹក) និងការទទួលបានបង្គន់អនាម័យប្រើប្រាស់ ។

ដោយបន្តនិន្នាការពីឆ្នាំ២០១៣ ក៏មានការកើនឡើងនូវចំនួនទីតាំងលំនៅឋានក្រីក្រនៅក្នុងខណ្ឌខាងក្រៅនៃរាជធានីភ្នំពេញផងដែរ។ និន្នាការនេះអាចមើលឃើញក្នុងតារាង និងក្រាហ្វិកខាងក្រោម។

[6] សហគមន៍ម៉ុងឌីយ៉ាល់ ក្រោមថ្មដា ក្ដីសង្ឃឹម ផ្លូវរថភ្លើង ដើមអំពិល ព្រែកតានូ សំបុកចាបបី ភូមិទ្រាបួន ក្បាលកោះនិរោធ ព្រែកតាគង់១ ភូមិព្រែកតានូ១ ក្បាលដំរី ស្វាយប៉ាក ភូមិ ១៤ និងឈ្មោះសហគមន៍ផ្សេងៗទៀតដែលមិនបានរៀបរាប់។

[7] ពេទ្យសម្ដេចឪ ផ្សារឌុយម៉ិច ភូមិ១២ បឹងត្របែកខាងកើត កូលាប ក្រោយរោងកុនភ្នំពេញ ភាពញញឹមនៃកុមារ តាង៉ូវលើ តាង៉ូវក្រោម ភូមិព្រែកតានូ២ ទីតាំងសហគមន៍នៅភូមិព្រែកតាគង់ ៣ទីតាំងសហគមន៍នៅភូមិក ភូមិក្រោលគោ ឆេកូ ក្រុម៨ ២ទីតាំងសហគមន៍នៅភូមិព្រែកតារ័ត្ន គៀនឃ្លាំង ខ្វារ ដីមាស ភូមិមិត្តភាព ភូមិលូ ទួលរ៉ាដា បុរីព្រែនគរ ត្រឡោកបែក ភូមិ៩ ក្រោយម៉ុងឌីយ៉ាល់ ផ្សារឃ្លាំងរំសេវ និងក្រុកស្លុង- និងឈ្មោះសហគមន៍ផ្សេងៗទៀតដែលមិនបានរៀបរាប់។

[8] បុរីកីឡា (អគារខាងក្រោយB) ២ទីតាំងសហគមន៍នៅអូរឫស្សីមួយ បឹងត្របែក គេ៨៧ ត្នោតជ្រុំ ប្រយូវង្ស ទួលរកាប៉ាស្វ័រ វិហារចាម ភូមិព្រែកតាសេក បុរី១០០ខ្នង និងឈ្មោះសហគមន៍ផ្សេងៗទៀតដែលមិនបានរៀបរាប់។

[9] ភូមិក ភូមិក(២) ភូមិក(៣) ។

**តួលេខទី ២៖** ចំនួនទីតាំងលំនៅឋានក្រីក្រនៅខណ្ឌខាងក្នុង និងខាងក្រៅឆ្នាំ ១៩៩៧-២០១៧




ចំនួនគ្រួសារក្រីក្រនៅរាជធានីក៏បានថយចុះផងដែរពីឆ្នាំ២០១៣ ដល់ឆ្នាំ២០១៧។ ជារួម មានការថយចុះចំនួន ៧ ៣៩៨ គ្រួសារ ឬស្មើនឹង២២% ពីការស្ទង់មតិក្នុងរាជធានីភ្នំពេញ ឆ្នាំ២០១៣។ ចំនួនខ្ពស់បំផុតគឺមកពីខណ្ឌខាងក្រៅដែលមានចំនួន ៨៨% នៃការថយចុះចំនួនគ្រួសារសរុប។

**តារាងទី ៣៖** ចំនួនគ្រួសារក្រីក្រនៅរាជធានីភ្នំពេញរវាងឆ្នាំ ១៩៩៧ និង ២០១៧

| **ខណ្ឌខាងក្នុង** | **១៩៩៧** | **២០០៣** | **២០០៩** | **២០១៣** | **២០១៧** |
|---|---|---|---|---|---|
| ៧ មករា | ១៧៦២ | ៣៨៧៥ | ១៨៨៤ | ៦១១ | ២៨៣ |
| ចំការមន | ៦៤៧៩ | ៨៥៧៤ | ២៤២១ | ២២៧០ | ២០៥១ |
| ដូនពេញ | ២៩៧០ | ៧១៨៨ | ២៣៣៧ | ៦១៤ | ១០៥៥ |
| ទួលគោក | ៣៤១១ | ៤៥៤០ | ៤៩២០ | ២២៨៨ | ១៩៩៤ |
| **សរុប** | **១៤៦២២** | **២៤១៧៧** | **១១៥៦២** | **៥៧៨៣** | **៤៨៨៣** |
| | **៤៨**% | **៣៩**% | **២៩**% | **១៧**% | **១៩**% |
| | | | | | |
| **ខណ្ឌខាងក្រៅ** | **១៩៩៧** | **២០០៣** | **២០០៩** | **២០១៣** | **២០១៧** |
| ច្បារអំពៅ | មិនមាន | មិនមាន | មិនមាន | មិនមាន | ២៣៩២ |
| ជ្រោយចង្វារ | មិនមាន | មិនមាន | មិនមាន | មិនមាន | ៨៦៧ |
| ដង្កោ | ៩០៣ | ១៩៦៩០ | ៧២៤២ | ៣៩៧៦ | ៤២៧០ |
| មានជ័យ | ៦៦៥៦ | ៥៣៨២ | ៩០០២ | ៧០១៧ | ២២៧៤ |
| ពោធិ៍សែនជ័យ | មិនមាន | មិនមាន | មិនមាន | ៤៥៥១ | ២៩១៥ |
| ព្រែកព្នៅ | មិនមាន | មិនមាន | មិនមាន | មិនមាន | ១៦៧៩ |

| | | | | | |
|---|---|---|---|---|---|
| ឫស្សីកែវ | ៧៩៦៩ | ១៣០០០ | ៨៤៨២ | ៦០២៣ | ៥២០០ |
| សែនសុខ | មិនមាន | មិនមាន | ៤២៦០ | ៦២៥៥ | ១៧២៧ |
| **សរុប** | **១៥៥២៨** | **៣៨០៧២** | **២៨៩៨៦** | **២៧៨២២** | **២១៣២៤** |
| | **៥២%** | **៦១%** | **៧១%** | **៨៣%** | **៨១%** |
| **សរុបរួម** | **១៩៩៧** | **២០០៣** | **២០០៩** | **២០១៣** | **២០១៧** |
| | **៣០១៥០** | **៦២២៤៩** | **៤០៥៤៨** | **៣៣៦០៥** | **២៦២០៧** |

ដូចករណីកាលពីឆ្នាំ២០១៣ ភាគច្រើននៃទីតាំងលំនៅឋានក្រីក្រ (៧១%) មិនបានរៀបចំចងក្រុងជាសហគមន៍ទេ។ ឧទាហរណ៍ផ្ទះនៅក្នុងទីតាំងលំនៅឋានក្រីក្របានរៀបចំចងក្រុងតាមរយៈគម្រោងសន្សំប្រាក់ ឬតាមវិធីសាស្ត្រផ្សេងៗទៀត ហើយមានមេដឹកនាំសហគមន៍។

## លក្ខណៈរួមនៃទីតាំងលំនៅឋានក្រីក្រ

តាមការស្ទង់មតិក្នុងរាជធានីភ្នំពេញឆ្នាំ២០១៣ ភាគច្រើននៃទីតាំងលំនៅឋានបានបង្កើតឡើងនៅចន្លោះឆ្នាំ១៩៧៩ និង២០០១។ ទីតាំងលំនៅឋានក្រីក្រនៅខណ្ឌខាងក្រៅមានចំនួនតិចតួច(១៣%) ដែលបានបង្កើតឡើងក្រោយឆ្នាំ២០០២ បន្ទាប់ពីមានការបណ្តេញចេញនូវទីតាំងលំនៅឋាននៅខណ្ឌខាងក្នុងជាច្រើនក្នុងទសវត្សរ៍ឆ្នាំ២០០០។

**តួលេខទី ៣៖** ឆ្នាំនៃការបង្កើតទីតាំងលំនៅឋានក្រីក្រ




(ចំនួន=២៧៧)

ភាគច្រើននៃទីតាំងលំនៅឋានក្រីក្រ (ទាំងនៅខណ្ឌខាងក្នុង និងខណ្ឌខាងក្រៅ)មានទំហំតូចនៅឡើយដោយ៦៤% នៃទីតាំងទាំងនោះមានសំណង់ត្រឹមចំនួន៥០ ឬតិចជាងនេះប៉ុណ្ណោះ។ នៅឆ្នាំ២០១៧ ខណ្ឌខាង

ក្នុងក៏មានចំនួនកើនឡើងនៃទីតាំងលំនៅឋានធំៗ(២២%) បើប្រៀបធៀបទៅនឹងឆ្នាំ២០១៣ (១០%) ។ វាដូចជាបង្ហាញថាលទ្ធផលនៃការកើនឡើងដង់ស៊ីតេទីតាំងលំនៅឋានកាន់តែខ្ពស់នៅខណ្ឌខាងក្នុង។

**តួលេខទី ៤៖** ចំនួននៃសំណង់អគារនៅក្នុងទីតាំងលំនៅឋានក្នុងឆ្នាំ២០១៧




(ចំនួន=២៧៧)

តំបន់ដែលនៅជាប់នឹងផ្ទៃទឹកគឺជាកន្លែងដែលមានទីតាំងក្រីក្រតាំងទីលំនៅច្រើនជាងគេក្នុងរាជធានីភ្នំពេញដោយមានទីតាំងលំនៅឋានក្រីក្រចំនួន ១០៨ នៅខណ្ឌខាងក្រៅ (៤៨%) និងចំនួន ២៥ នៅខណ្ឌខាងក្នុង (៤៣%) ។

**តួលេខទី ៥៖** ការប្រើប្រាស់ដីមុនពេលការបង្កើតទីតាំងលំនៅឋានក្រីក្រ




(ចំនួន =២៧៧)

មានទីតាំងលំនៅឋានសរុបចំនួន ១៣១ (៤៧%) នៅទីតាំងជាប់នឹងប្រភពទឹកមួយចំនួន (ទន្លេ ស្ទឹង បឹង និងស្រះធម្មជាតិ ឬសិប្បនិម្មិត) និងមានទីតាំងចំនួន១៧ ស្ថិតនៅជាប់នឹងផ្លូវដែក ដែលជាងពាក់កណ្តាលច្រើនជាងឆ្នាំ២០១៣ (៣១ទីតាំង)។ ទីតាំងលំនៅឋាននៅលើដំបូលអគារមានការថយចុះគួរឱ្យកត់សម្គាល់ផងដែរ ដែលបច្ចុប្បន្នមានចំនួនត្រឹមតែ ៤ប៉ុណ្ណោះដែលត្រូវបានកត់ត្រា បើប្រៀបធៀបទៅនឹងឆ្នាំ២០១៣ មានចំនួន ១៣ ទីតាំងដែលស្ថិតនៅក្នុងខណ្ឌខាងក្នុង។

ជនជាតិខ្មែរជាក្រុមដែលមានចំនួនច្រើនជាងគេចំនួន៧៧% និងមានចំនួនតែ១៩%ប៉ុណ្ណោះដែលជាក្រុមចម្រុះជាតិសាសន៍នៅក្នុងទីតាំងលំនៅឋានក្រីក្រដែលបានរកឃើញ។ ក្នុងចំណោមទីតាំងលំនៅឋានរបស់ជនជាតិភាគតិចចម្រុះ ក្រុមជនជាតិភាគតិចសំខាន់ៗ គឺជនជាតិវៀតណាម និងចិន ដែលរស់នៅខណ្ឌខាងក្នុង និងជនជាតិវៀតណាម ចាម និងកម្ពុជាក្រោមនៅខណ្ឌខាងក្រៅ។

**តួលេខទី ៦៖** ក្រុមជនជាតិភាគតិចសំខាន់ៗនៅក្នុងទីតាំងលំនៅឋាន




(ចំនួន=២៧៧)

## លទ្ធផលរកឃើញសំខាន់ៗ

- ជាទូទៅចំនួនទីតាំងលំនៅឋានរបស់ក្រីក្របានបន្តថយចុះពី ៤១០ ទៅ២៧៧ (ថយចុះ ៣២%) ចាប់តាំងពីឆ្នាំ២០០៩ មក។ មូលហេតុចម្បងនៃការថយចុះនេះ (៥៣% នៃទីតាំងលំនៅឋាន) គឺដោយសារតែភាពប្រសើរឡើងនៃលក្ខខណ្ឌលំនៅឋាន (ឧទាហរណ៍៖ ពួកគេមិនត្រូវបានចាត់ទុកថាជាប្រជាជនក្រីក្រទៀតទេ) ។
- និន្នាការនៃការកើនឡើងនូវចំនួនទីតាំងលំនៅឋានក្រីក្រក្នុងខណ្ឌខាងក្រៅ និងការថយចុះដែលត្រូវគ្នានៅក្នុងខណ្ឌខាងក្នុងបានបន្តចាប់តាំងពីឆ្នាំ២០០៩ មក។ បច្ចុប្បន្នខណ្ឌខាងក្រៅមានចំនួនទីតាំងលំនៅឋានក្រីក្រចំនួន ៧៩% ហើយក្នុងឆ្នាំ២០០៩ មានចំនួន ៦៩% ។

# ៤. ការកាន់កាប់ និងការចេញប័ណ្ណកម្មសិទ្ធិដីធ្លី និងការតាំងទីលំនៅថ្មី

## ប្រភេទដីធ្លី និងប័ណ្ណកម្មសិទ្ធិដីធ្លី



កម្មករក្រុមហ៊ុនកំពុងសាងសង់ព្រំប្រទល់របស់ក្រុមហ៊ុនដើម្បីចាក់ដីខ្សាច់បំពេញនៅសហគមន៍ព្រៃកតាគង់ ផ្លូវ៦០ម៉ែត្រ ឆ្នាំ២០១៧

### ប្រភេទដី

នៅប្រទេសកម្ពុជាដីត្រូវបានបែងចែកជាបីប្រភេទសំខាន់ៗ ដូចតាមការកំណត់ដោយច្បាប់ភូមិបាលឆ្នាំ២០០១៖[10]

- ដីរដ្ឋ៖ ដីរដ្ឋត្រូវបានចែកជាពីរដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ។ ដីសាធារណៈរបស់រដ្ឋ គឺជាដីដែលត្រូវបានកាន់កាប់ដោយរដ្ឋសម្រាប់ជាផលប្រយោជន៍ និងបម្រើសាធារណៈជនទូទៅប្រើប្រាស់ដែលមានដូចជាផ្លូវថ្នល់ ផ្លូវដែក ទីតាំងបេតិកភណ្ឌ សាលារៀន មន្ទីរពេទ្យ និងអគាររដ្ឋបាលជាដើម។

[10] សម្រាប់ការពិភាក្សាកាន់តែលម្អិតពីប្រភេទដីធ្លី សូមមើល៖ អង្គការសមាគមធាងត្នោត (២០១៣) "គោលនយោបាយសម្រាប់ប្រជាជនក្រីក្រ"ភ្នំពេញ សន្តិសុខសិទ្ធិកាន់កាប់ដីធ្លី និងសារាចរលេខ ០៣

ដីឯកជនរបស់រដ្ឋ គឺជាដីដែលមិនមែនសម្រាប់បម្រើប្រយោជន៍សាធារណៈទេ។ ដីឯកជនរបស់រដ្ឋអាចត្រូវបានជួលឬលក់បាន ប៉ុន្តែដីសាធារណៈរបស់រដ្ឋមិនអាចជាកម្មសិទ្ធិរបស់នរណាម្នាក់ទេ។

- ដីឯកជន៖ ជាដីធ្លីដែលជាកម្មសិទ្ធិ ឬកាន់កាប់ដោយភាគីឯកជន។
- ដីសមូហភាព៖ ដីធ្លីដែលជាកម្មសិទ្ធិរបស់ជនជាតិដើមភាគតិច(តាមសហគមន៍) ឬវត្តអារាមនានា។

## ប្រភេទប័ណ្ណកម្មសិទ្ធិដីធ្លី

ទាក់ទងទៅនឹងភាពជាម្ចាស់កម្មសិទ្ធឯកជននៃដីធ្លី ភស្តុតាងនៃកម្មសិទ្ធិដែលមិនអាចប្រកែកបាន គឺជាវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុដែលជាទូទៅគេហៅថាប្លង់រឹង៖

- ប្លង់រឹង គឺជាវិញ្ញាបនបត្រផ្លូវការបញ្ជាក់ពីសិទ្ធិជាម្ចាស់កម្មសិទ្ធដែលបានចុះបញ្ជី និងចេញដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់(MLMUPC)។ វាមានលក្ខណៈទទួលស្គាល់ និងមិនអាចប្រកែកបានចំពោះកម្មសិទ្ធភាព និងសិទ្ធក្នុងការចាត់ចែងផ្សេងៗទៅលើដីនោះ។
- ប្លង់ទន់ ជាប្រភេទឯកសារដែលបានមកពីឯកសារផ្ទេរដីធ្លី(កិច្ចសន្យាដែលមានសាក្សីជាផ្លូវការលិខិតទទួល និងឯកសារផ្សេងៗទៀត) ដែលបានចុះបញ្ជីនៅថ្នាក់សង្កាត់(ក្រុមប្រឹក្សា) និងខណ្ឌ។ ប្លង់ទន់នេះគឺជាការទទួលស្គាល់នូវការកាន់កាប់ដីធ្លី ប៉ុន្តែវាមិនមែនជាប្លង់កម្មសិទ្ធិផ្លូវការនោះទេ។ នៅក្នុងរាជធានីភ្នំពេញ មានទីតាំងដីធ្លីជាច្រើនដែលគ្មានអ្នកណាបានដឹងពីស្ថានភាពផ្នែកច្បាប់ថាជាប្រភេទអ្វី។ ប្រជាពលរដ្ឋជាច្រើនបានរស់នៅក្នុងផ្ទះរបស់ពួកគេដោយមានការអនុញ្ញាតពីអាជ្ញាធរមូលដ្ឋាន ឬកិច្ចសន្យាលក់ដីរបស់គេមិនមានគេទទួលស្គាល់។ បញ្ហានេះបង្កឱ្យមានបញ្ហាប្រឈមសំខាន់ៗសម្រាប់អ្នកក្រីក្រដែលរស់នៅតាមទីតាំងក្រីក្រទាំងនោះ ដូចជាអសុវត្ថិភាពលើបញ្ហាដីធ្លី កង្វះខាតក្នុងការទទួលបានសេវាសាធារណៈផ្សេងៗ និងឥណទានជាដើម។

# លទ្ធផលរកឃើញ

## ប្រភេទដីធ្លី

៩០% នៃទីតាំងលំនៅឋានក្រីក្រនៅរាជធានីភ្នំពេញបានឱ្យដឹងថា ពួកគេដឹងពីប្រភេទដីដែលពួកគេរស់នៅ។ ភាគច្រើន (៦៣%) បានបង្ហាញថាទីតាំងលំនៅឋានរបស់ពួកគេស្ថិតនៅលើដីឯកជនដែលជាកម្មសិទ្ធិរបស់ប្រជាពលរដ្ឋ។ ភាគច្រើន(៦៦%)នៃទីតាំងលំនៅឋានក្រីក្រ អាជ្ញាធរមូលដ្ឋានរួមទាំងប្រធានភូមិ មន្ត្រីថ្នាក់សង្កាត់ និងថ្នាក់ខណ្ឌ បានប្រាប់ឱ្យពួកគេបានដឹងពីប្រភេទដី ដែលពួកគេកំពុងរស់នៅ ។

**តួលេខទី ៧៖** ប្រភេទដីធ្លីដែលបានសង់លំនៅឋាន




(ចំនួន=២៧៧)

## ប្លង់កម្មសិទ្ធិ

ភាគច្រើន (៨៣%) នៃទីតាំងលំនៅឋានក្រីក្រនៅរាជធានីភ្នំពេញបាននិយាយថាពួកគេមិនមានឯកសារជាលាយលក្ខណ៍អក្សរ ដើម្បីកំណត់ពីស្ថានភាពដីធ្លីរបស់ពួកគេទេ។ ទាក់ទងទៅនឹងទីតាំងលំនៅឋាន មាន ៧៥% មិនបានចុះបញ្ជីដីធ្លីជាប្រព័ន្ធ។ ក្នុងចំណោមទីតាំងលំនៅឋានទាំងនោះមានចំនួន ៣៩ទីតាំងប៉ុណ្ណោះដែលបានចុះបញ្ជីដីធ្លីជាប្រព័ន្ធ។ ពួកគេបានទទួលប័ណ្ណកម្មសិទ្ធិ ដូច្នេះពួកគេត្រូវបានទទួលស្គាល់ថាជាម្ចាស់ដីធ្លីស្របច្បាប់។ ទីតាំងលំនៅឋាននៅខណ្ឌខាងក្រៅមាន ៣០ទីតាំង ច្រើនជាងនៅខណ្ឌខាងក្នុង ដែលមានតែ៩ទីតាំង បានទទួលប័ណ្ណកម្មសិទ្ធិ។ ទោះបីយ៉ាងណាក៏ដោយ នៅឆ្នាំ២០១៥ ការសិក្សាពីស្ថានភាពសេដ្ឋកិច្ចសង្គមកម្ពុជា បានរកឃើញថា ៩១,៧% នៃលំនៅឋានក្នុងរាជធានីភ្នំពេញត្រូវបានគ្រប់គ្រងជាម្ចាស់កម្មសិទ្ធិ[11]។

[11] ការសិក្សាពីសេដ្ឋកិច្ចសង្គមកម្ពុជារបស់វិទ្យាស្ថានជាតិស្ថិតិក្នុងឆ្នាំ២០១៥ នៃប្រទេសកម្ពុជា។ដកស្រង់ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៨ ពី៖ https://www.nis.gov.kh/index.php/en/about/general-information/14-cses/12-cambodia-socio-economic-survey-reports

**តួលេខទី ៨៖** ទីតាំងលំនៅឋានដែលបាន ចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ




(ចំនួន=២៦៤)

## ការផ្លាស់ប្តូរលំនៅឋាន

អ្នកក្រីក្រនៅរាជធានីភ្នំពេញរស់នៅក្នុង៤១ ទីតាំង (១៥%)បានរាយការណ៍ថា ទីតាំងលំនៅឋានរបស់ពួកគេកំពុងប្រឈមនឹងការបណ្តេញចេញ និង ឬរងសម្ពាធក្នុងការឱ្យផ្លាស់ប្តូរលំនៅឋាន។ នេះរួមបញ្ចូលទាំងការគំរាមកំហែងបណ្តេញចេញផ្សេងៗទាំងផ្លូវការ និងមិនផ្លូវការ។ មានតែ១៥% នៃទីតាំងលំនៅឋានដែលប្រឈមនឹងការបណ្តេញចេញ ឬការផ្លាស់ប្តូរលំនៅឋានបានបញ្ជាក់ថា ពួកគេបានទទួលព័ត៌មានផ្លូវការ (កិច្ចប្រជុំផ្លូវការ ឬការជូនដំណឹងជាផ្លូវការ)។ ដូច្នេះ ព័ត៌មានភាគច្រើនដែលពួកគេបានទទួលគឺតាមរយៈការនិយាយតៗគ្នាក្រៅផ្លូវការ អត្ថបទប្រព័ន្ធផ្សព្វផ្សាយ ឬពាក្យចចាមអារ៉ាម។ ទាំងនេះមិនមែនជាសញ្ញាច្បាស់លាស់ទេដែលថាប្រជាពលរដ្ឋនឹងត្រូវគេបណ្តេញចេញ ប៉ុន្តែវាអាចធ្វើឱ្យប្រជាពលរដ្ឋមានអារម្មណ៍មិនមានសុវត្ថិភាពចំពោះសិទ្ធិកាន់កាប់ដីធ្លី។

**តួលេខទី៩៖** ទម្រង់នៃការជូនដំណឹង




(ចំនួន=៤១ នៃ២៧៧ មិនមានការឆ្លើយតបពីខណ្ឌខាងក្រៅពីអ្នកផ្តល់ចម្លើយ “កិច្ចប្រជុំផ្លូវការ”)

ទីតាំងលំនៅឋានភាគច្រើន (៧៧%) បានបង្ហាញថា មូលហេតុនៃការបណ្តេញចេញ ឬផ្លាស់ប្តូរលំនៅឋាន គឺដើម្បីអភិវឌ្ឍសម្រាប់ប្រយោជន៍សាធារណៈ។

**តួលេខទី១០៖** មូលហេតុចំពោះការបណ្តេញចេញ ឬការផ្លាស់ប្តូរលំនៅឋាន




(ចំនួន=៣៨)

**តារាងទី ៤៖ មូលហេតុនៃការបណ្តេញចេញ ឬការផ្លាស់ប្តូរលំនៅឋាន**

| មូលហេតុ | ខណ្ឌខាងក្នុង | ខណ្ឌខាងក្រៅ |
|---|---|---|
| ការសាងសង់អគារ | ១៧% | ១២% |
| ការពង្រីកផ្លូវដែលមានស្រាប់ | ៣៣% | ៣៥% |
| ការសាងសង់ស្ពាន ឬផ្លូវថ្មី | ០% | ៤% |
| ការស្តា និងកែលម្អប្រឡាយ | ១៧% | ៨% |
| ការធ្វើកែលម្អច្រាំងទន្លេ | ០% | ១២% |
| ការកែលម្អសម្រស់ទីក្រុង | ១៧% | ៤% |
| ផ្សេងៗ | ១៧% | ២៧% |
| | ១០០% | ១០០% |

លើសពីនេះទៅទៀត ប្រជាពលរដ្ឋភាគច្រើនដែលត្រូវបានស្ទង់មតិ(៧៨%)នៃទីតាំងលំនៅឋានក្រីក្របានឱ្យដឹងថា ពួកគេមិនដែលបានឮពីសារាចរលេខ ០៣ ទេ។[12] មានតែទីតាំងលំនៅឋានចំនួន ១៧ ប៉ុណ្ណោះបានបង្ហាញថា ពួកគេធ្លាប់ដឹងពីសារាចរលេខ ០៣ ដែលភាគច្រើន តាមរយៈកិច្ចប្រជុំជាមួយអាជ្ញាធរមូលដ្ឋាន។

## លទ្ធផលរកឃើញសំខាន់ៗ

- ៦៣% នៃទីតាំងលំនៅឋានក្រីក្រនៅរាជធានីភ្នំពេញបានបង្ហាញថា ទីតាំងលំនៅឋានរបស់ប្រជាពលរដ្ឋរស់នៅលើដីឯកជនដែលជាកម្មសិទ្ធិរបស់ខ្លួន។
- ៨៥% នៃទីតាំងលំនៅឋានក្រីក្រនៅរាជធានីភ្នំពេញបានបង្ហាញថា ប្រជាពលរដ្ឋមិនមានឯកសារជាលាយលក្ខណ៍អក្សរកំណត់ពីស្ថានភាពដីធ្លីរបស់ខ្លួនទេ។
- ១៥% នៃទីតាំងលំនៅឋានក្រីក្រនៅរាជធានីភ្នំពេញបានបង្ហាញថា ប្រជាពលរដ្ឋកំពុងប្រឈមនឹងការបណ្តេញចេញ និង ឬរងសម្ពាធក្នុងការផ្លាស់ប្តូរលំនៅឋាន។

[12] ចេញផ្សាយក្នុងឆ្នាំ ២០១០ សារាចរ ០៣ ស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋដែលបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់នៅតាមរាជធានី ទីក្រុង និងទីប្រជុំជន បានផ្តល់ជាក្របខ័ណ្ឌសម្រាប់ដោះស្រាយបញ្ហានៃទីតាំងលំនៅឋានខុសច្បាប់ កាប់កាប់លើដីរដ្ឋ។ ទោះជាយ៉ាងណាក៏ដោយ ភាពមិនច្បាស់លាស់ទាក់ទងនឹងទីតាំងរបស់ខ្លួនក្នុងច្បាប់ភូមិបាល និងរបៀបអនុវត្តច្បាប់ជាក់ស្តែងបានកាត់បន្ថយប្រសិទ្ធភាពរបស់ច្បាប់នេះ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។

# ៥. រចនាសម្ព័ន្ធលំនៅឋាន ហេដ្ឋារចនាសម្ព័ន្ធ និងសេវាផ្សេងៗ

ជំពូកនេះ វាយតំលៃស្ថានភាពហេដ្ឋារចនាសម្ព័ន្ធ និងការផ្តល់សេវាកម្មដោយមានការប្រៀបធៀបរវាងខណ្ឌខាងក្នុង និងខាងក្រៅនៅនៃរាជធានីភ្នំពេញ។



ហេដ្ឋារចនាសម្ព័ន្ធសហគមន៍បន្ទាយស្លឹក ឆ្នាំ២០១៧

## លទ្ធផលរកឃើញ

### សម្ភារៈសម្រាប់សាងសង់លំនៅឋាន

ការចាត់ថ្នាក់ប្រភេទសម្ភារៈសម្រាប់កសាងលំនៅឋានត្រូវបានផ្អែកលើការស្រាវជ្រាវពីមុនស្តីពីការតាំងទីលំនៅរបស់ប្រជាជនក្រីក្រនៅភ្នំពេញឆ្នាំ២០១៣ ដែលក្នុងនោះត្រូវបានចាត់ថ្នាក់ជាប្រភេទផ្សេងៗដូចជាឈើ ស័ង្កសី ថ្ម សម្ភារៈចម្រុះដែលមានគុណភាពខ្ពស់ សម្ភារៈចម្រុះដែលមានគុណទាប[13] និងសម្ភារៈចាស់ៗ ដែលសំដៅលើប្លាស្ទិច កំណាត់សំពត់ បំណែកឈើដែលធ្លាប់ប្រើប្រាស់ និងផ្ទាំងដែកចាស់ៗជាដើម។

[13] ការបែងចែកគុណភាពអន់ ឬគុណភាពខ្ពស់គឺអាស្រ័យដោយការវិនិច្ឆ័យ(មើលនឹងភ្នែក)នៃលំនៅឋាន។ ឧទាហរណ៍៖គុណភាពទាបដោយការប្រើប្រាស់ដែកស័ង្កសីចាស់ៗ សម្ភារៈបាក់បែក ឬសម្ភារៈធ្លុះធ្លាយផ្សេងៗដើម្បីការពារភ្លៀងមិនឱ្យចូលផ្ទះរបស់គេ។

ជាទូទៅនៅតាមតំបន់ទីតាំងក្រីក្រ សម្ភារៈសម្រាប់យកទៅសាងសង់លំនៅឋានប្រមាណជាង ៣០% គេប្រើប្រាស់សម្ភារៈចម្រុះដែលមានគុណភាពទាប។ ខណៈពេលដែលមានការស្រាវជ្រាវមួយទៀតកាលពីឆ្នាំ ២០១៥ ដែលមានចំណងជើងថា ស្ថានភាពសេដ្ឋកិច្ចសង្គមកម្ពុជា បានរកឃើញថា ៧៦,២% រស់នៅក្នុងលំនៅឋានដែលធ្វើអំពីថ្ម ចំណែកឯ១៨,៤%ទៀត ធ្វើអំពីឈើ ប៉ុន្តែមិនបានចែងស្តង់ដារនៃប្រភេទសម្ភារៈនោះទេ។ លើសពីនេះទៀត ដំបូលផ្ទះរបស់ប្រជាពលរដ្ឋនៅតាមទីតាំងក្រីក្រភាគច្រើនគឺធ្វើអំពីស័ង្កសីដែលមានប្រមាណជា ៥៤,២% ហើយ ១៧,៩% ទៀតធ្វើអំពីបេតុង និងប្រក់ក្បឿង។

**តួលេខទី១១៖** សម្ភារៈសំខាន់ៗសម្រាប់សាងសង់លំនៅឋាន




(ចំនួន=២៧៧)

## ហេដ្ឋារចនាសម្ព័ន្ធទីតាំងលំនៅឋាន(ផ្លូវចូល)

ជាទូទៅផ្លូវចេញចូលសម្រាប់ទីតាំងលំនៅឋានក្រីក្រក្នុងរាជធានីភ្នំពេញ គឺជាច្រកតូចៗ ដែលមានទំហំល្មមសម្រាប់តែម៉ូតូមួយគ្រឿងប៉ុណ្ណោះ (៤៨%) ។ ដូចអ្វីដែលបានគិតទុក ខណ្ឌខាងក្រៅមានទំហំផ្លូវចេញចូលល្អប្រសើរជាង ដោយផ្លូវដែលអាចឡានមួយចេញចូលបានមានទៅដល់៣៤% ចំណែកខណ្ឌខាងក្នុងមានតែ ១៩%ប៉ុណ្ណោះ ។ ចំពោះភ្លើងបំភ្លឺផ្លូវវិញ មានទីតាំងលំនៅឋានក្រីក្រតែ ១២% ដែលមានភ្លើងបំភ្លឺនៅពេលយប់ ហើយភាគច្រើនគឺនៅខណ្ឌខាងក្នុង។

**តួលេខទី១២៖** ប្រភេទផ្លូវចូលទៅទីតាំងលំនៅឋាន




(ចំនួន=២៧៧)

## ហេដ្ឋារចនាសម្ព័ន្ធទីតាំងលំនៅឋាន (ប្រព័ន្ធលូបង្ហូរទឹក)

ប្រព័ន្ធលូបង្ហូរទឹកគឺជាបញ្ហាសម្រាប់ទីតាំងលំនៅឋាននៅខណ្ឌខាងក្រៅ ដែលមាន៤៦% បានរាយ-ការណ៍ថា ពួកគេគ្មានប្រព័ន្ធលូបង្ហូរទឹកភ្លៀង ឬលាមកទេ ប្រសិនធ្វើការប្រៀបធៀប តាំងលំនៅឋានក្រីក្រនៅខណ្ឌខាងក្នុងមានតែ១៨% ប៉ុណ្ណោះបាននិយាយថាពួកគេគ្មានប្រព័ន្ធលូបង្ហូរទឹក ។ ភាគច្រើននៃទីតាំងលំនៅឋានក្នុងខណ្ឌខាងក្នុង (៧៥%) ប្រើប្រាស់ប្រព័ន្ធលូបង្ហូរទឹកក្រោមដីហើយមានតែ ៤៥% ប៉ុណ្ណោះនៅខណ្ឌខាងក្រៅប្រើប្រាស់ប្រព័ន្ធលូបង្ហូរទឹកក្រោមដី។ ទិន្នន័យក៏បង្ហាញផងដែរថា អាជ្ញាធរសង្កាត់ គឺជាកម្លាំងចលករមួយជួយផ្តល់ហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធនឹងប្រព័ន្ធលូបង្ហូរទឹក ដោយក្នុងនោះ ៤១% នៃប្រព័ន្ធលូគាំទ្រដោយអាជ្ញាធរផ្ទាល់។ ទីតាំងចំនួន ២៥% បានកសាងហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធនឹងប្រព័ន្ធលូបង្ហូរទឹកដោយប្រើប្រាស់ថវិកាផ្ទាល់ខ្លួនរបស់ពួកគេ។ បើទោះបីជាយ៉ាងណាក៏ដោយ ដោយសារតែមិនមានទិន្នន័យស្រដៀងគ្នាសម្រាប់រាជធានីភ្នំពេញ យើងមិនអាចយកទីតាំងតំបន់ក្រីក្រទាំងនោះទៅប្រៀបធៀបទៅនឹងទីតាំងផ្សេងទៀតនៅក្នុងរាជធានីភ្នំពេញបានទេ។ យោងទៅតាមរបាយការណ៍របស់ធនាគារពិភពលោក ដែលមានចំណងជើងថា "ការអភិវឌ្ឍទីក្រុងភ្នំពេញ" (២០១៧) ប្រព័ន្ធលូនៅក្នុងខណ្ឌខាងក្រៅគឺមិនទាន់គ្រប់គ្រាន់នៅឡើយ ដូច្នេះអាចនិយាយបានថា ហេដ្ឋារចនាសម្ព័ន្ធរបស់ខណ្ឌខាងក្រៅនៅមានការខ្វះខាតសម្រាប់ប្រជាជន និងតំបន់ទាំងនោះ។

**តួលេខទី១៣៖** ប្រភេទនៃប្រព័ន្ធលូបង្ហូរទឹកសម្រាប់ទឹកភ្លៀង និងលាមក




(ចំនួន=២៧៧)

ជាទូទៅ ៥៥% ទីតាំងលំនៅឋានក្រីក្រនៅរាជធានីភ្នំពេញត្រូវបានរងផលប៉ះពាល់ដោយទឹកជន់លិចយ៉ាងហោចណាស់ម្តងក្នុងរដូវវស្សា ដោយខណ្ឌខាងក្នុង និងខាងក្រៅត្រូវបានរងផលប៉ះពាល់ក្នុងកម្រិតប្រហាក់ប្រហែលគ្នា(៥២%ខណ្ឌខាងក្នុង និង៥៦%ខណ្ឌខាងក្រៅ)។ ៣៥%នៃចំនួនទីតាំងខណ្ឌខាងក្រៅ អាចមានរយៈពេលជន់លិចយូរជាងគឺរហូតដល់ច្រើនជាងបួនសប្តាហ៍។ ទោះបីយ៉ាងណាស្ថិតិនេះគឺវាពិបាកនឹងប្រៀបធៀបថាតើការជន់លិច បានល្អប្រសើរឡើង ឬអាក្រក់ជាងពេលមុននៅតំបន់ទីតាំងអ្នកក្រីក្រទាំងនោះ។

**តួលេខទី១៤៖** ចំនួនពេលវេលាសម្រាប់ទឹកលិចហូរអស់អំឡុងពេលរដូវវស្សា




(ចំនួន=២៧៧)

## ហេដ្ឋារចនាសម្ព័ន្ធទីតាំងលំនៅឋាន( បង្គន់អនាម័យ )

ភាគច្រើននៃទីតាំងលំនៅឋានក្រីក្រនៅរាជធានីភ្នំពេញ មានបង្គន់អនាម័យប្រើប្រាស់ផ្ទាល់ខ្លួន(៨៥%) ដែលចំនួននេះបង្ហាញថាវាល្អប្រសើរជាងការស្ទង់មតិក្នុងរាជធានីភ្នំពេញឆ្នាំ២០១៣។ មានតែទីតាំងលំនៅឋានចំនួន ១៨ ប៉ុណ្ណោះ (មកពីខណ្ឌខាងក្រៅ) ដែលគ្មានលទ្ធភាពទទួលបានបង្គន់អនាម័យប្រើប្រាស់មានន័យថាវាក៏ល្អប្រសើរជាងការស្ទង់មតិឆ្នាំ២០១៣ដែលបានថយចុះពី៣៧ទីតាំង។

**តួលេខទី១៥៖** បង្គន់អនាម័យ នៅទីតាំងលំនៅឋាន




(ចំនួន=២៧៦ *មិនមានចម្លើយពីខណ្ឌខាងក្នុងដែលឆ្លើយថា “គ្មាន” ទេ)

## សេវាប្រមូលសំរាម

ការប្រមូលកាកសំណល់រឹង ឬសំរាមនៅតែមិនទាន់គ្រប់គ្រាន់ដោយមានទីតាំងលំនៅឋានចំនួន ១០០ គ្មានសេវាប្រមូលសំរាម។ នៅក្នុងខណ្ឌខាងក្រៅ ទីតាំងលំនៅឋានចំនួន៩២ មិនមានសេវាប្រមូលសំរាមទេ។ ទោះជាយ៉ាងណាក៏ដោយ នេះជាការល្អប្រសើរជាងការស្ទង់មតិនៅឆ្នាំ២០១៣ ដែលទីតាំងចំនួន ២០២ (១៨៨ ខណ្ឌខាងក្រៅ) មិនមានសេវាប្រមូលសំរាម។

**តួលេខទី១៦៖** ភាពញឹកញាប់នៃការប្រមូលសំរាម




(ចំនួន=២៧៦)

## សេវាទឹកស្អាត

ទីតាំងលំនៅឋាននៅខណ្ឌខាងក្នុង ដែលបានតភ្ជាប់បណ្តាញទឹកស្អាតរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ មានភាគរយខ្ពស់ (៨៨%) បើប្រៀបធៀបទៅនឹងខណ្ឌខាងក្រៅ (៧២%) ។ ការមានការតភ្ជាប់បណ្តាញទឹកស្អាត មានន័យថា បណ្តាញទឹកបានទៅដល់ទីតាំងលំនៅឋានទាំងនោះ។ វាមិនប្រាកដថាតើគ្រួសារនីមួយៗបានតភ្ជាប់បណ្តាញទឹកដោយផ្ទាល់នោះទេ។ ខណៈពេលដែលទីតាំងលំនៅឋាននៅខណ្ឌខាងក្នុង៧% មិនដែលធ្លាប់មានការតភ្ជាប់ បណ្តាញទឹកស្អាតនោះ សម្រាប់ខណ្ឌខាងក្រៅមានចំនួនដល់ទៅ២៤%។ ជាថ្មីម្តងទៀត វាជាការបង្ហាញពីភាពខុសគ្នាខ្លាំងនៅក្នុងការផ្តល់សេវាកម្មរវាងខណ្ឌខាងក្នុង និងខាងក្រៅ។ ប្រជាពលរដ្ឋបានរាយការណ៍ថា ការចំណាយជាមធ្យមសម្រាប់ការផ្គត់ផ្គង់ទឹកស្អាត គឺ ១៨០០រៀល (០,៤២ ដុល្លារអាមេរិក) ក្នុងមួយម៉ែត្រគូប ហើយការចំណាយជាមធ្យមសម្រាប់ទឹកស្អាតមួយពាងគឺ ៦ ៧៨០រៀល (១,៧០ ដុល្លារអាមេរិក) ។

**តួលេខទី១៧៖** លទ្ធភាពទទួលបានការផ្គត់ផ្គង់ទឹកស្អាតប្រើប្រាស់




(ចំនួន=២៧៥)

## សេវាអគ្គិសនី

ទីតាំងលំនៅឋានចំនួន៩២%បានតភ្ជាប់បណ្តាញអគ្គីសនីកម្ពុជា(EDC)របស់រដ្ឋ។ នេះមិនមានន័យថា គ្រួសារនីមួយៗបានតភ្ជាប់បណ្តាញអគ្គិសនីដោយផ្ទាល់នោះទេ ប៉ុន្តែជាការតភ្ជាប់បណ្តាញអគ្គិសនីទៅដល់ទីតាំងរបស់ពួកគេតែប៉ុណ្ណោះ។ ភាគរយខ្ពស់នៃទីតាំងលំនៅឋានទាំងនោះនៅក្នុងខណ្ឌខាងក្រៅមិនដែលបានតភ្ជាប់បណ្តាញអគ្គីសនីរបស់រដ្ឋទេ មានចំនួនសរុប១៤ទីតាំង បើប្រៀបធៀបទៅនឹងទីតាំងខណ្ឌខាងក្នុង មានចំនួនតែ៥ប៉ុណ្ណោះដែលមិនមានប្រើប្រាស់អគ្គីសនីរដ្ឋ។ ប្រជាពលរដ្ឋបានរាយការណ៍ថា ថ្លៃអគ្គិសនីជាមធ្យមគឺ ១ ៤២៧ រៀល ក្នុងមួយគីឡូវ៉ាត់ម៉ោង ។

**តួលេខទី១៨៖** លទ្ធភាពទទួលបានអគ្គិសនីប្រើប្រាស់




## លទ្ធផលរកឃើញសំខាន់ៗ

- ហេដ្ឋារចនាសម្ព័ន្ធ និងការផ្តល់សេវានៅខណ្ឌខាងក្រៅនៅតែខ្វះខាតខ្លាំងជាង ខណ្ឌខាងក្នុង ជាពិសេស ប្រព័ន្ធលូបង្ហូរទឹក បង្គន់អនាម័យ ការប្រមូលសំរាម និងលទ្ធភាពទទួលបានទឹកស្អាតប្រើប្រាស់។
- ប្រព័ន្ធលូបង្ហូរទឹក គឺជាបញ្ហា ជាពិសេសនៅខណ្ឌខាងក្រៅ ដែល ៤១% នៃទីតាំងលំនៅឋានក្រីក្រនៅរាជធានីមិនមានប្រព័ន្ធលូបង្ហូរទឹកទេ។ ទោះជាយ៉ាងណាក៏ដោយ នេះគឺជាការល្អប្រសើរមួយចាប់ពីឆ្នាំ ២០១៣ មក ដែលមានការថយចុះពី ៦០% នៃទីតាំងលំនៅឋានក្រីក្រនៅរាជធានីភ្នំពេញដែលគ្មានប្រព័ន្ធលូបង្ហូរទឹក ។

- ទឹកលិចនៅតែជាបញ្ហាមួយផងដែរ ដោយមាន ៥៥% នៃទីតាំងលំនៅឋានក្រីក្រនៅរាជធានីភ្នំពេញជួបប្រទះនឹងទឹកលិចយ៉ាងហោចណាស់ម្តង ក្នុងអំឡុងពេលបីរដូវវស្សាចុងក្រោយនេះ ។
- ៣៦%នៃទីតាំងលំនៅឋានក្រីក្រនៅរាជធានីភ្នំពេញ នៅតែមិនមានការប្រមូលសំរាមទេ ទោះជាយ៉ាងណា នេះគឺជាការល្អប្រសើរមួយគួរឱ្យកត់សំគាល់ ជាងឆ្នាំ២០១៣ដែលមាន៥៩%។
- មានចំនួនស្រដៀងគ្នានៃទីតាំងលំនៅឋាននៅខណ្ឌខាងក្នុង និងខាងក្រៅបានតភ្ជាប់បណ្តាញអគ្គីសនីរបស់រដ្ឋ ខណៈដែលភាគរយខ្ពស់នៃទីតាំងលំនៅឋាននៅខណ្ឌខាងក្នុងមាន (៨៨%) បើប្រៀបធៀបទៅនឹងខណ្ឌខាងក្រៅ (៧២%) បានតភ្ជាប់បណ្តាញអគ្គិសនីរបស់រដ្ឋ។

# ៦. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ចំនួនទីតាំងលំនៅឋានក្រីក្រនៅរាជធានីភ្នំពេញបានថយចុះចាប់តាំងពីឆ្នាំ២០០៩ ហើយនេះបង្ហាញពីឥទ្ធិផលនៃការការអភិវឌ្ឍផ្សេងៗ។ ខណៈពេលដែលទីតាំងលំនៅឋានជាច្រើនបានបាត់រូបរាងដោយសារតែការបណ្តេញចេញ និងការផ្លាស់ប្តូរលំនៅឋានដោយការអភិវឌ្ឍ ការស្ទង់មតិក្នុងរាជធានីភ្នំពេញឆ្នាំ២០១៧ បានបង្ហាញពីភាពវិជ្ជមានដោយសារតែចំនួនទីតាំងលំនៅឋាន ដែលកំពុងកើនឡើងបានទទួលនូវលក្ខខណ្ឌជីវភាពរស់នៅប្រសើរឡើង ហើយមិនត្រូវបានចាត់ទុកថា "ក្រីក្រ" ទៀតទេ។

ទោះជាយ៉ាងណាក៏ដោយ ទីតាំងលំនៅឋានក្រីក្រនៅទីនៅក្នុងរាជធានីភ្នំពេញចំនួន ២៧៧ នៅតែប្រឈមនឹងបញ្ហាជាច្រើន។ ភាគច្រើនមិនមានឯកសារជាលាយលក្ខណ៍អក្សរដើម្បីកំណត់ស្ថានភាពដីធ្លីរបស់ពួកគេ និងសិទ្ធិក្នុងការទទួលបានព័ត៌មានត្រឹមត្រូវទាក់ទងនឹងសិទ្ធិកាន់កាប់ដីធ្លីដែលធ្វើឱ្យពួកគេកាន់តែងាយរងគ្រោះ និងងាយទទួលរងការបណ្តេញចេញ ឬការផ្លាស់ប្តូរលំនៅឋាន។ ជាងនេះទៅទៀត ស្ទើរតែពាក់កណ្តាលនៃទីតាំងលំនៅឋានក្រីក្រគឺស្ថិតនៅក្បែរផ្ទៃទឹក(បឹង ទន្លេ ប្រឡាយ) ដែលមានន័យថាសិទ្ធិក្នុងការកាន់កាប់ដីធ្លីរបស់ពួកគេទំនងជាប្រឈមនឹងបញ្ហាផ្លូវច្បាប់ដោយសារការរស់នៅលើដីសាធារណៈរបស់រដ្ឋ(ដែលជាធម្មតាគ្របដណ្តប់ដោយផ្ទៃទឹក)។

## អនុសាសន៍

### សាលារាជធានីភ្នំពេញ

ផ្តល់ និងគាំទ្រក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ និងការផ្តល់សេវាកម្មកាន់តែប្រសើរឡើងក្នុងទីតាំងលំនៅឋានក្រីក្រដោយផ្តោតលើខណ្ឌខាងក្រៅ។ ការផ្តល់អាទិភាពមួយចំនួនគួររួមមានប្រព័ន្ធលូបង្ហូរទឹក ការប្រមូលសំរាម និងការតភ្ជាប់បណ្តាញទឹកស្អាតរបស់រដ្ឋ។

### ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ និងការិយាល័យភូមិបាលខណ្ឌ

- ប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការអនុវត្តប្រកបដោយតម្លាភាព និងជួយសម្របសម្រួលការចុះបញ្ជីដីធ្លីមានលក្ខខណៈជាប្រព័ន្ធ និងការចេញប័ណ្ណកម្មសិទ្ធិដីធ្លី។
- ធ្វើការកែលម្អទីតាំងលំនៅឋានក្រីក្រនៅនឹងកន្លែងជាជម្រើសចម្បង ផ្ទុយពីការបណ្តេញចេញ និងជម្រើសផែនការសុវត្ថិភាពកាន់កាប់ដីធ្លីផ្សេងៗទៀតដែលអាចធ្វើបាន នៅពេលដែលការកែលម្អនៅនឹងកន្លែងមិនអាចធ្វើទៅរួច។

## ដៃគូអភិវឌ្ឍន៍

- បង្កើតកម្មវិធីដើម្បីជួយសហគមន៍ក្រីក្រឱ្យទទួលបានសិទ្ធិទទួលបានសិទ្ធិកាន់កាប់ដីធ្លី លក្ខខណ្ឌជីវភាពរស់នៅ និងដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិតសម្រាប់ប្រជាពលរដ្ឋ ដែលមិនមានសិទ្ធិកាន់កាប់ដីធ្លី។
- សម្រាប់សហគមន៍ដែលស្ថិតនៅលើដីសាធារណៈរបស់រដ្ឋគួរតែរៀបចំឱ្យមានយុទ្ធនាការក្នុងការអនុវត្តសារាចរ០៣ ដូច្នេះដំណោះស្រាយផ្សេងៗអាចត្រូវបានរៀបចំឡើង តាមរយៈការពិភាក្សា និងការសិក្សាស្រាយជ្រាវផ្សេងៗ។
- ធានាថា វិធីសាស្ត្ររួមមួយត្រូវបានគេយកមកប្រើប្រាស់ ជាមួយអាជ្ញាធររដ្ឋដើម្បីជម្រុញឱ្យមានការដោះស្រាយបញ្ហាដីធ្លីទាំងនេះ។

# ៧. ផែនទីនៃទីតាំងលំនៅឋានក្រីក្រនៅរាជធានីភ្នំពេញ





URBAN POOR SETTLEMENT CHAMKAR MON DISTRICT
CHAMKAR MON
CMN01 Krom 16
CMN02 Boeng Keng Kang Muoy
CMN03 Wat Than
CMN04 Tumnob Toek
CMN05 Samaki RungRoeung
CMN06 Boeng Trabek
CMN07 Boeng Tompun
CMN08 Boeng Trabek
CMN09 Spean Chheu
CMN10 Plov 101
CMN11 Phum Prampi
CMN12 Mohamontrey
CMN13 Tuol Svayprey Muoy
CMN14 Phsar Leu
CMN15 Boeng Trabek
CMN16 Phum Pram
CMN17 Wat Prayuvong
CMN18 Boeng Trabek
CMN19 Boeng Trabek
Legend
Urban poor settlements
Roads
Railway
District boundaries
Commune boundaries
River/lake
Meters
Coordinate System: WGS1984 UTM Zone 48N
Projection: Transverse Mercator
Datum: WGS1984
Scale: 1:25,000
Cartographer: Yem Sokchear
Survey team: Mr. Justin Flurscheim, Mr. Sron Thay and ten data collectors
Date: 28/02/2018
Sources
STT: Urban poor settlements (2017); ODC: Phnom Penh Boundary(2014) ; District Boundaries (2014); Communities Boundaries (2014); Openstreetmap.org: Phnom Penh areas (2013),Roads (2014); Unknown: Railway, River/lake
CHAMKAR MON
TUOL KORK
7 MAKARA
DANG KOR
CHROY CHANGVA
LVEA AEM
Tumnob Tuek
Tuol Svay Prey Ti Pir
Tuol Svay Prey Ti Muoy
Olympic
Boeng Keng Kang Ti Pir
Boeng Keng Kang Ti Bei
Boeng Keng Kang Ti Muoy
Tuol Tumpung Ti Pir
Tuol Tumpung Ti Muoy
Boeng Trabaek
Phsar Daeum Thkov
Tonle Basak
Mao Tse Toung Blvd (St:245)
Preah Norodom Blvd (St: 41)
Preah Sihanouk Blvd (St:274)
Sothearos Blvd
Preah Sisowath Quay
Street 271
Street 369
National Road No 2
National Highway 1
1,274,000
1,276,000
1,278,000
490,000
492,000
494,000


URBAN POOR SETTLEMENT DAUN PENH DISTRICT
DAUN PENH
DP01 Boeung Kak
DP02 Plov Ratespleung
DP03 Heam Cheat
DP04 Blok Tampa
DP05 Soriya Mall
DP06 Phum Dobmuoy
DP07 N/A
DP08 Krom Spean
DP09 Deung Heam 53
DP10 Phum Bey
DP11 Phum Prambey
DP12 Krom 16
DP13 Plov Ratespleung
Legend
Urban poor settlements
Roads
Railway
District boundaries
Commune boundaries
River/lake
Meters
Coordinate System: WGS1984 UTM Zone 48N
Projection: Transverse Mercator
Datum: WGS1984
Scale: 1:22,500
Cartographer: Yem Sokchear
